**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងពាណិជ្ជកម្ម
លេខ ២៧៣ ព.ណ ភស៣.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងាររៀបចំគោលនយោបាយជាតិជំឡួងមី

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម។

## សម្រេច

**ប្រការ ១ :** បង្កើតក្រុមការងាររៀបចំគោលនយោបាយជាតិជំឡួងមី សម្រាប់ជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ប៉ាន សូរស័ក្តិ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២. ឯកឧត្តម | **ម៉ៅ ថូរ៉ា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣. លោកជំទាវ | **ស្វ ស្រីម៉ិច** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៤. ឯកឧត្តម | **ម៉ែន សុទិដ្ឋាតិ** | អគ្គនាយកពាណិជ្ជកម្មក្នុងប្រទេស នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥. ឯកឧត្តម | **កើត សុធា** | អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន | សមាជិក |
| ៦. ឯកឧត្តម | **ហឿង សុគន្ធ** | អភិបាលរង នៃគណៈអភិបាលខេត្តបាត់ដំបង | សមាជិក |
| ៧. ឯកឧត្តម | **ម៉ែន កុសល្យ** | អភិបាលរង នៃគណៈអភិបាលខេត្តត្បូងឃ្មុំ | សមាជិក |

| | | | |
|---|---|---|---|
| ៨. លោក | **ប្រាក់ ជាតិថូ** | អគ្គនាយករងកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩. លោក | **រាម ច័ន្ទវណ្ណា** | អគ្គនាយករងសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១០. លោក | **សារិ ផល្លា** | ប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១១. លោក | **សៀង ចំណាន** | អនុប្រធាននាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២. លោក | **សុក វណ្ណា** | អនុប្រធាននាយកដ្ឋានដំណាំឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣. លោក | **សុខ ហេង** | អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៤. លោក | **អ៊ុក តូលា** | អនុប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៥. លោក | **ឌី សំអាន** | អនុប្រធាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៦. លោក | **ជាង ហុង** | ព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម នៃសាកលវិទ្យាភូមិន្ទកសិកម្ម | សមាជិក |
| ១៧. បណ្ឌិត | **ស្រ៊ាន ពៅ** | ព្រឹទ្ធបុរសស្តីទីមហាវិទ្យាល័យកសិកម្ម និងកែច្នៃអាហារ នៃសាកលវិទ្យាល័យបាត់ដំបង | សមាជិក |
| ១៨. លោក | **នី ភន** | ប្រធានសម្ព័ន្ធសមាគមដំឡូងមីសំពៅលូន | សមាជិក |
| ១៩. លោក | **ប្រាក់ ដេវីត** | នាយកគ្រប់គ្រងក្រុមហ៊ុនដំឡូងមីបាត់ដំបង (BAI) | សមាជិក |
| ២០. លោក | **ហេង សារ៉ាត់** | អគ្គនាយករង ក្រុមហ៊ុនដំឡូងមី TTY | សមាជិក |
| ២១. លោក | **ប្រាក់ មុររ៉ែត** | នាយកគ្រប់គ្រងគម្រោងក្រុមហ៊ុន IDEMITSU | សមាជិក |
| ២១. តំណាងអង្គការ ឬដៃគូអភិវឌ្ឍន៍ | | | សមាជិក |

**ប្រការ ២ :** **ក្រុមការងារ មានភារកិច្ចដូចតទៅ**

- សិក្សាស្រាវជ្រាវ តាមដានវឌ្ឍនភាពការងារដំឡូងមី
- រៀបចំឯកសារគោលនយោបាយជាតិដំឡូងមី ជូនរាជរដ្ឋាភិបាល
- អនុវត្តន៍គោលនយោបាយជាតិដំឡូងមី
- ពិនិត្យ និងតាមដានការអនុវត្តគោលនយោបាយជាតិដំឡូងមី
- សម្របសម្រួលសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ក្នុងការកៀរគរជំនួយជាបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់ចូលរួមអនុវត្តន៍គោលនយោបាយជាតិដំឡូងមី
- ចូលរួមរៀបចំព្រឹត្តការណ៍ជំរុញពាណិជ្ជកម្ម លើវិស័យដំឡូងមី ដូចជា រៀបចំទិវាជាតិដំឡូងមីកម្ពុជា ជំនួបដៃគូពាណិជ្ជកម្មក្រៅប្រទេស សិក្ខាសាលា សន្និសីទ។ល។

**ប្រការ ៣** : ក្រុមការងារនេះប្រើប្រាស់ថវិកាជាតិ ដែលជាកញ្ចប់ថវិការបស់ក្រសួងពាណិជ្ជកម្ម និងថវិកាហិរញ្ញប្បទានដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍នានា និងថវិកាពីប្រភពផ្សេងៗ ទៀត ដែលច្បាប់អនុញ្ញាត។

**ប្រការ ៤** : ក្រុមការងារនេះ មានលេខាធិការដ្ឋាន នៅក្នុងនាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. លោក | **គិត តារ៉ា** | ប្រធាននាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម | ប្រធាន |
| ២. លោក | **អួង សុខន** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន | អនុប្រធាន |
| ៣. លោក | **សួន ទិដ្ឋា** | ប្រធានវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ | អនុប្រធាន |

**ភារកិច្ចរបស់លេខាធិការដ្ឋានមានដូចតទៅ៖**

- រៀបចំផែនការសកម្មភាពការងារសម្រាប់ជំរុញការអនុវត្តគោលនយោបាយជំឡូងមី
- សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បីរៀបចំសិក្ខាសាលា បេសកកម្មពាណិជ្ជកម្ម វេទិកាជំរុញការវិនិយោគលើវិស័យជំឡូងមីទាំងក្នុង និងក្រៅប្រទេស
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំ បេសកកម្មពាណិជ្ជកម្ម ជំនួបស្វែងរកដៃគូពាណិជ្ជកម្ម សិក្ខាសាលា និងសន្និសីទលើវិស័យជំឡូងមី ជូនក្រុមការងាររៀបចំគោលនយោបាយជំឡូងមី ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ណែនាំបន្ត
- ធ្វើការជាមួយដៃគូអភិវឌ្ឍន៍ និងជំនាញការតាមវិស័យនីមួយៗ ដើម្បីធ្វើគោលនយោបាយជំឡូងមីសម្រាប់ដាក់ជូនក្រុមការងារពិនិត្យ និងផ្តល់យោបល់
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់ប្រធានក្រុមការងារ។

**ប្រការ ៥**. នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរខេត្តគោលដៅ និងសាមីខ្លួនដូចមានក្នុងប្រការ១ និងប្រការ៤ ត្រូវអនុវត្តន៍តាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**ចម្លងជូន៖**

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួងឧស្សាហកម្ម និងសិប្បកម្ម*
- *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*
- *រដ្ឋបាលខេត្តប៉ៃលិន*
- *រដ្ឋបាលខេត្តបាត់ដំបង*
- *រដ្ឋបាលខេត្តត្បូងឃ្មុំ "**ដើម្បីជូនជ្រាប**"*
- *ដូចប្រការ១ និងប្រការ៤ "**ដើម្បីអនុវត្ត**"*
- *ឯកសារ-កាលប្បវត្តិ*